AMRO
ASEAN +3 MACROECONOMIC RESEARCH OFFICE

10 Shenton Way
#15-08, MAS Building
Singapore 079117
T: +65 6323 9844
F: +65 6223 8187
www.amro-asia.org

# ទស្សនវិស័យសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ឆ្នាំ ២០១៧

## សេចក្តីសង្ខេប

### ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

ខណៈដែលសេដ្ឋកិច្ចក្នុងតំបន់អាស៊ានបូកបីអាចបញ្ចៀសបាននូវការប៉ះទង្គិចពីខាងក្រៅបានយ៉ាងល្អប្រសើរ ក្នុងឆ្នាំ ២០១៦ ភាពមិនប្រាកដប្រជានៃគោលនយោបាយសកលក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ជាពិសេស ទស្សនវិស័យពាណិជ្ជកម្មសកល តាមរយៈការកើនឡើងនៃការគាំពារពាណិជ្ជកម្ម (Trade protectionism)។ ទីផ្សារហិរញ្ញវត្ថុសកលនៅតែបន្តមានភាពប្រែប្រួលខ្លាំង ហើយកំពុងជះឥទ្ធិពលទៅលើប្រទេស ដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ក្នុងតំបន់ (Emerging markets)។

- ទោះបីជាបណ្តាប្រទេសធំៗនៅលើសកលលោកកំពុងតែមានសន្ទុះកំណើនសេដ្ឋកិច្ចល្អជាងមុនក៏ដោយ ក៏ការងើបឡើងវិញនេះនៅតែអាចរងផលប៉ះពាល់ពីភាពមិនប្រាកដប្រជានៃគោលនយោបាយសកល។ នៅសហរដ្ឋអាមេរិក គោលនយោបាយជំរុញកំណើនសេដ្ឋកិច្ចរបស់រដ្ឋាភិបាលដែលដឹកនាំដោយ លោក ត្រាំ (Trump Administration) ហាក់មានសក្តានុពលវិជ្ជមានចំពោះសេដ្ឋកិច្ចសហរដ្ឋអាមេរិក ទោះបីជាគោលនយោបាយរឹតបន្តឹងផ្នែកពាណិជ្ជកម្ម និងអន្តោប្រវេសន៍ (Immigration policies) អាចនឹងជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចក៏ដោយ។ នៅសហភាពអឺរ៉ុប សន្ទុះកំណើនសេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ និងចក្រភពអង់គ្លេស មានភាពរឹងមាំជាងការរំពឹងទុក ប៉ុន្តែយើងនៅតែមានការព្រួយបារម្ភ ចំពោះទស្សនវិស័យសេដ្ឋកិច្ច មុនការបោះឆ្នោតនៅក្នុងបណ្តាប្រទេសសំខាន់ៗក្នុងតំបន់ចាយប្រាក់អឺរ៉ូ និងការចរចាលើការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) នាពេលខាងមុខ។
- ភាពមិនប្រាកដប្រជានៃគោលនយោបាយសកលបានជះឥទ្ធិពលដល់សេដ្ឋកិច្ចតំបន់អាស៊ានបូកបី តាមបណ្តាញពាណិជ្ជកម្ម និងហិរញ្ញវត្ថុ (Trade and financial channels)។ ចំពោះផលប៉ះពាល់តាមបណ្តាញពាណិជ្ជកម្ម បើទោះជាមានសញ្ញានៃការងើបឡើងវិញនៃពាណិជ្ជកម្ម និងតម្លៃទំនិញសកលក៏ដោយ ក៏ការ-ងើបឡើងវិញនេះនៅតែស្ថិតក្រោមការគំរាមកំហែង ដែលអាចបណ្តាលមកពីការគាំពារពាណិជ្ជកម្មរបស់រដ្ឋាភិបាលដែលដឹកនាំដោយ លោក ត្រាំ ដោយហេតុថាការគាំពារពាណិជ្ជកម្មនេះ ហាក់ផ្តោតសំខាន់ទៅលើសេដ្ឋកិច្ចក្នុងតំបន់អាស៊ានបូកបី ដែលមានអតិរេកពាណិជ្ជកម្មជាមួយសហរដ្ឋ-អាមេរិក។ ចំពោះផលប៉ះពាល់តាមបណ្តាញហិរញ្ញវត្ថុវិញ ស្ថានភាពហិរញ្ញវត្ថុសកលមានភាពរឹតបន្តឹងជាមួយនឹងការដំឡើង

អត្រាការប្រាក់គោលរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិក ខណៈដែលភាពមិនប្រាកដប្រជានៃគោលនយោបាយកំពុងជំរុញឱ្យមានភាពប្រែប្រួលកាន់តែខ្លាំងនៅលើទីផ្សារហិរញ្ញវត្ថុ និងហានិភ័យនៃលំហូរចេញនៃមូលធនពីបណ្តាប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ទាំងអស់។

កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសចិន និងជប៉ុន ត្រូវបានរំពឹងថានឹងរក្សាបាននូវស្ថិរភាពនៅក្នុងឆ្នាំ ២០១៧ ទោះបីជាប្រឈមនឹងហានិភ័យនៃការកើនឡើងនៃការគាំពារពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកក៏ដោយ។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសទាំង ២ នឹងរួមចំណែករក្សាលំនឹងកំណើនសេដ្ឋកិច្ចក្នុងតំបន់អាស៊ានបូកបី ដែលត្រូវបានរំពឹងថានឹងថយចុះបន្តិចបន្តួចមកត្រឹមប្រមាណ ៥,២% និង ៥,១% នៅក្នុងឆ្នាំ២០១៧ និង ២០១៨ រៀងគ្នា។

- ក្នុងរយៈពេលដ៏ខ្លីខាងមុខ (Short term) កំណើនសេដ្ឋកិច្ចប្រទេសចិនអាចនឹងមានស្ថិរភាព ខណៈដែលរដ្ឋាភិបាលកំពុងបន្តអនុវត្តគោលនយោបាយកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយថ្លៃផលិត (Producer prices) បានងើបឡើងខ្ពស់នាពេលថ្មីៗនេះ។ ស្ថិរភាពនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន នឹងបន្តរួមចំណែករក្សាលំនឹងកំណើនសេដ្ឋកិច្ចតំបន់អាស៊ានបូកបី ព្រមទាំងស្រូបយកការនាំចូលពីតំបន់ផងដែរ។ ជាទស្សនវិស័យ ការបង្កើនល្បឿននៃកំណែទម្រង់សហគ្រាសរដ្ឋ (State-owned enterprise reform), ការបន្តកាត់បន្ថយផលិតកម្មឧស្សាហកម្មដែលច្រើនលើសហួសតម្រូវការ (Industrial overcapacity reduction), ការកាត់បន្ថយបំណុលសាជីវកម្ម និងការកាត់បន្ថយហានិភ័យស្ថិរភាពហិរញ្ញវត្ថុ នឹងនៅតែជាបញ្ហាប្រឈមគន្លឹះសម្រាប់ប្រទេសចិន ។
- ចំណែកឯប្រទេសជប៉ុនវិញ កំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថា នឹងរក្សាបាននូវភាពរឹងមាំក្នុងឆ្នាំ ២០១៧ ហើយអាចមានកម្រិតខ្ពស់ជាងកំណើនសក្តានុពល (Potential Growth) ដែលគាំទ្រដោយគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងតម្រូវការពីក្រៅប្រទេស។ ជាមួយនឹងគោលនយោបាយរូបិយវត្ថុផ្ទុយគ្នា ដោយសារតែអត្រាការប្រាក់ប័ណ្ណរតនាគារអាមេរិក (US treasury yield)ចេះតែកើនឡើង និងមានកម្រិតប្រហាក់ប្រហែលនឹងអត្រាការប្រាក់នៃសញ្ញាប័ណ្ណរដ្ឋាភិបាលជប៉ុន (JGB yield) រួមនឹងកត្តារចនាសម្ព័ន្ធផ្សេងៗទៀត វិនិយោគផលបត្រពីប្រទេសជប៉ុនត្រូវបានរំពឹងថា នឹងបន្តហូរចេញទៅកាន់តំបន់អាស៊ានបូកបី។
- ការសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រ (Empirical work) របស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (AMRO) ដែលធ្វើការប្រៀបធៀបការជះឥទ្ធិពលពីសេដ្ឋកិច្ចសហរដ្ឋអាមេរិក, ចិន និង ជប៉ុន ដោយប្រើម៉ូដែល Global Vector Autoregressive (GVAR) បានបង្ហាញឱ្យឃើញថា ការប៉ះទង្គិចផ្នែកសេដ្ឋកិច្ច (Real economy shocks) ពីសហរដ្ឋអាមេរិក និងចិន ទៅលើការនាំចេញពីតំបន់អាស៊ានបូកបី មានឥទ្ធិពលខ្លាំងជាងការប៉ះទង្គិចពីជប៉ុន។ ជាងនេះទៅទៀត ឥទ្ធិពលនៃការប៉ះទង្គិច ពីចិនមានភាពយូរអង្វែងជាងឥទ្ធិពលនៃការប៉ះទង្គិចពីសហរដ្ឋអាមេរិក។ ការសិក្សាក៏បានបង្ហាញផងដែរថា

ភាពតានតឹងចំពោះវិស័យសាជីវកម្ម (Stresses to the corporate sector) ដែលមានប្រភពមកពីនៅសហរដ្ឋអាមេរិក ចិន និងជប៉ុន ក៏ជាបណ្តាញចំលងដ៏ចម្បងនៃភាពតានតឹងទាំងនោះ (Channels of stress transmission) ទៅលើវិស័យហិរញ្ញវត្ថុ និងសាជីវកម្មរបស់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីក-លូតលាស់ក្នុងតំបន់។

ជាមួយនឹងទស្សនវិស័យមិនច្បាស់លាស់ផ្នែកពាណិជ្ជកម្ម កំណើនសេដ្ឋកិច្ចក្នុងតំបន់ត្រូវបានរំពឹងថានឹងបន្តគាំទ្រជាចម្បងដោយតម្រូវការក្នុងស្រុក គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ។ ទន្ទឹមនេះ ទ្រនាប់ទុនបម្រុងអន្តរជាតិរបស់សេដ្ឋកិច្ចក្នុងតំបន់ (Foreign exchange reserve buffers) ក៏នៅមានទំហំគ្រប់គ្រាន់ផងដែរ។ ទោះជាយ៉ាងនេះក្តី បើធៀបនឹងឆ្នាំ២០១៦ លទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ ជារួមមានកម្រិតទាបជាងមុន។

- ទោះបីជាតាមបទដ្ឋានអន្តរជាតិ ទ្រនាប់ទុនបម្រុងអន្តរជាតិនៅមានកម្រិតខ្ពស់ធៀបនឹងការនាំចូល និងបំណុលក្រៅប្រទេសរយៈពេលខ្លីក៏ដោយ ក៏ប្រទេសនីមួយៗក្នុងតំបន់គួររក្សាទ្រនាប់ទុនបម្រុងអន្តរជាតិក្នុងកម្រិតមួយសមស្រប ខណៈពេលដែលប្រទេសទាំងនេះកំពុងទទួលរងនូវសម្ពាធនៃលំហូរចេញនៃមូលធនទៅក្រៅប្រទេស។ ការលក់ចេញភ្លាមៗនូវទ្រព្យសកម្មជារូបិយវត្ថុក្នុងស្រុក និងការដកចេញមូលធនក្នុងស្ថានភាពលែងប្រថុយប្រថាន (Risk-off scenario) ពីសំណាក់វិនិយោគិនបរទេស នឹងបន្ថែមសម្ពាធទៅលើអត្រាប្តូរប្រាក់ និងទុនបម្រុងអន្តរជាតិ។ ដើម្បីឆ្លើយតបឱ្យបានសមរម្យទៅនឹងហានិភ័យដែលបណ្តាលមកពីការប៉ះទង្គិចពីខាងក្រៅ ប្រទេសនានាក្នុងតំបន់គួរបន្តប្រកាន់យកនូវរបបអត្រាប្តូរប្រាក់ដែលអាចបត់បែនបាន គួបផ្សំនឹងអន្តរាគមន៍ពីសំណាក់អជ្ញាធរពាក់ព័ន្ធ ដើម្បីទប់ល្បឿននៃការកែតម្រូវនានា។
- ចំពោះគោលនយោបាយរូបិយវត្ថុវិញ បើប្រៀបធៀបនឹងឆ្នាំ ២០១៦ ការកើនឡើងនៃអតិផរណា និងការ-រឹតបន្តឹងលក្ខខណ្ឌរូបិយវត្ថុសកលនៅឆ្នាំ ២០១៧ នឹងធ្វើឱ្យប្រទេសនានាក្នុងតំបន់កាន់តែមានការលំបាកក្នុងការប្រើប្រាស់គោលនយោបាយរូបិយវត្ថុ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ទន្ទឹមនេះ បណ្តាប្រទេសនានាដែលភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ (Financial vulnerabilities) កាន់តែមានការកើនឡើងដោយសារកំណើនខ្ពស់នៃឥណទាន ឬបំណុលក្រៅប្រទេស នឹងត្រូវធ្វើការជ្រើសរើស រវាងការរក្សាការប្រើប្រាស់គោលនយោបាយរូបិយវត្ថុទ្រទ្រង់ (Accommodative monetary policy) និងការរក្សាស្ថិរភាពហិរញ្ញវត្ថុ។
- គោលនយោបាយសារពើពន្ធអាចនឹងដើរតួនាទីកាន់តែសំខាន់ជាងមុន ក្នុងការកាត់បន្ថយហានិភ័យដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច (downside risks to the real economy) ទោះបីជាលទ្ធភាពនៃការអនុវត្តគោលនយោបាយសារពើពន្ធជាមានកម្រិតទាបជាងមុនក៏ដោយ។ ដោយឡែក

ប្រទេសមួយចំនួនក្នុងតំបន់ដែលមានការលំបាកក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ ដោយសារការរឹតបន្តឹងនៃបទបញ្ញត្តិសារពើពន្ធ (Fiscal rules) មួយចំនួន។ បន្ថែមពីនេះ ប្រទេសក្នុងតំបន់ ដែលមានបំណុលសាធារណៈកម្រិតទាប (lower public debt) និងស្ថានភាពខាងក្រៅរឹងមាំ (Stronger external positions) គួរពិចារណាពង្រីកគោលនយោបាយសារពើពន្ធរបស់ខ្លួន ក្នុងកម្រិតមួយសម-ស្រប។ ផ្ទុយទៅវិញ សេដ្ឋកិច្ចដែលពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ ដើម្បីទ្រទ្រង់គណនីចរន្ត និងតុល្យភាពសារពើពន្ធ "ឱនភាពភ្លោះ - Twin Deficits" អាចប្រឈមនឹងបញ្ហាហិរញ្ញប្បទានកាន់តែពិបាកជាងមុន នៅពេលដែលប្រទេសទាំងនេះព្យាយាមពង្រីកគោលនយោបាយសារពើពន្ធ។

- ស្ថិតក្នុងបរិការណ៍នៃសេដ្ឋកិច្ចសកលដែលប្រកបដោយភាពមិនប្រាកដប្រជានាពេលបច្ចុប្បន្ននេះ និងស្ថានភាពដែលតម្រូវឱ្យមានការពិចារណារជ្រើសរើសរវាងកំណើនសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ អ្នករៀបចំគោលនយោបាយគួរតែផ្តល់អាទិភាពដល់ការរក្សាស្ថិរភាពហិរញ្ញវត្ថុជាចំបង។ ដោយសារលទ្ធភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិត អ្នករៀបចំគោលនយោបាយតំបន់គួរពិចារណាប្រើប្រាស់ឡើងវិញនូវវិធានការគោលនយោបាយម៉ាក្រូប្រុងប្រយ័ត្នជាក់លាក់ណាមួយ (Targeted macroprudential policy measures) ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។ ដោយហេតុថា គោលនយោបាយគ្រប់គ្រងតម្រូវការរយៈពេលខ្លីនៅមានកម្រិតនៅឡើយ (short-term demand management policies) អ្នករៀបចំគោលនយោបាយគួរតែបង្កើនល្បឿននៃការកែទម្រង់រចនា-សម្ព័ន្ធរបស់ខ្លួន។

## ប្រធានបទស្នូលៈ សេដ្ឋកិច្ចតំបន់អាស៊ានបូកបី ក្នុងអំឡុងពេល២០ឆ្នាំបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ី

- ឆ្នាំ ២០១៧ ជាឆ្នាំទី ២០ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុអាស៊ី (AFC) ដែលវិបត្តិនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលបានកែប្រែមូលដ្ឋាន និងមាគ៌ានៃកំណើនសេដ្ឋកិច្ច និងសមាហរណកម្មតំបន់ ក៏ដូចជាចក្ខុវិស័យរបស់អ្នករៀបចំគោលនយោបាយ ចំពោះការគ្រប់គ្រង និងដោះស្រាយវិបត្តិ។ ជាពិសេស AFC បានបង្ហាញពីតម្រូវការចាំបាច់ជាបន្ទាន់ លើកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុតំបន់ ដើម្បីគ្រប់គ្រង និងដោះស្រាយវិបត្តិ។ ជាលទ្ធផល គំនិតផ្តួចផ្តើមឈៀងម៉ៃ (Chiang Mai Initiative - CMI) ត្រូវបានបង្កើតឡើងក្រោមយន្តការហិរញ្ញវត្ថុអាស៊ានបូកបី ដែលក្រោយមកត្រូវបានពង្រីកទៅជាកិច្ចព្រមព្រៀងពហុនីយ-កម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (Chiang Mai Initiative Multilateralisation - CMIM) និងឈានទៅដល់ការបង្កើតការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូកបី (ASEAN+3 Macroeconomic Research Office - AMRO) ដែលដើរតួនាទីជាអង្គភាពឃ្លាំមើលស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឯករាជ្យមួយ ដើម្បីទ្រទ្រង់កិច្ចព្រមព្រៀង CMIM។

- អំឡុងពេលមួយទសវត្សរ៍បន្ទាប់ពី AFC (១៩៩៧ - ២០០៦) គឺជាដំណាក់កាលនៃការពង្រឹងសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីទទួលរងផលប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរ និងជាដំណាក់កាលកសាងឡើងវិញនូវមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ច។ មាគ៌ាស្តារឡើងវិញនៅពេលនោះ បានតម្រូវឱ្យមានការកែតម្រូវរបបអត្រាប្តូរប្រាក់ (Exchange rate regime), ការកែទម្រង់វិស័យសាជីវកម្ម និងហិរញ្ញវត្ថុ (Corporate and financial sector reforms), ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយសារពើពន្ធ (Fiscal Consolidation) និងការកែទម្រង់បទបញ្ញត្តិប្រុងប្រយ័ត្ននានា (Prudential regulation)។ ការកែតម្រូវគោលនយោបាយ និងកំណែកទម្រង់ទាំងនេះ បានអនុញ្ញាតឱ្យសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ ធ្វើការកសាងឡើងវិញនូវមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយយកការនាំចេញជាកត្តាជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច។
- ការបន្តគោលនយោបាយបើកចំហរបស់តំបន់ ចំពោះវិស័យពាណិជ្ជកម្ម, វិនិយោគផ្ទាល់ពីបរទេស និងលំហូរមូលធន បន្ទាប់ពី AFC បានជំរុញឱ្យសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ាន (Developing ASEAN economies) អាចទាញយកផលប្រយោជន៍ពីសមាហរណកម្មតំបន់ដែលកំពុងតែរីកលូតលាស់ និងការលេចឡើងនៃវត្តមានរបស់ប្រទេសចិននៅក្នុងតំបន់ ក្នុងវិស័យពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស នៅអំឡុងពេលមួយទសវត្សរ៍ក្រោយពីវិបត្តិហិរញ្ញវត្ថុសកល (GFC) បើទោះបីជាតម្រូវការសកល ជាពិសេសតម្រូវការពីប្រទេសអភិវឌ្ឍន៍ ដូចជាតំបន់ចាយប្រាក់អឺរ៉ូ និងសហរដ្ឋអាមេរិក បានធ្លាក់ចុះក៏ដោយ។ ទន្ទឹមនឹងនេះដែរ លំហូរមូលធននៅក្នុងតំបន់ក៏បានកើនឡើងផងដែរ ដោយប្រទេសជប៉ុនបានដើរតួនាទីជាម្ចាស់កម្ចីផង និងជាវិនិយោគិនចម្បងមួយផង នៅក្នុងតំបន់អាស៊ានបូកបី។
- លំហូរមូលធនរវាងបណ្តាប្រទេសក្នុងតំបន់ (Intra-regional financial flows) បានកើនឡើងក្នុងអំឡុងពេលដែលមានការអនុវត្តគោលនយោបាយរូបិយវត្ថុជំរុញក្នុងទ្រង់ទ្រាយធំ (Massive monetary policy stimulus) នៅសហរដ្ឋអាមេរិក និងតំបន់ចាយប្រាក់អឺរ៉ូ ដែលបានជួយសម្រួលដល់ដំណើរការនៃការផ្លាស់ប្តូររបស់ប្រទេសក្នុងតំបន់អាស៊ានបូកបី ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើការនាំចេញ ទៅជាសេដ្ឋកិច្ចដែលពឹងផ្អែកលើតម្រូវការក្នុងស្រុក។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃលំហូរចូលនៃមូលធនជាច្រើនបន្តបន្ទាប់ បានបង្កឱ្យមានការកើនឡើងនៃភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុ (Financial vulnerabilities), ធ្វើឱ្យមានការប្រែប្រួលកាន់តែខ្លាំងក្នុងទីផ្សារហិរញ្ញវត្ថុ និងបង្កភាពស្មុគស្មាញក្នុងការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ។ ដើម្បីគ្រប់គ្រប់គ្រងហានិភ័យនៃស្ថិរភាពហិរញ្ញវត្ថុបាន និងបន្តទាញយកផលប្រយោជន៍ពីលំហូរចូលនៃមូលធន អ្នករៀបចំគោលនយោបាយក្នុងតំបន់អាស៊ានបូកបី បានក្លាយជាអ្នកប្រើប្រាស់វិធានការប្រុងប្រយ័ត្នម៉ាក្រូសេដ្ឋកិច្ចយ៉ាងសកម្មបំផុតមួយផងដែរក្នុងពិភពលោក។

- ស្ថិតក្នុងបរិការណ៍នៃសេដ្ឋកិច្ចសកលដែលប្រកបដោយភាពមិនប្រាកដប្រជានាពេលបច្ចុប្បន្ននេះ បទពិសោធន៍ពី AFC នាពេលកន្លងមក បានផ្ដល់នូវមេរៀនដ៏មានតម្លៃជាច្រើនដល់អ្នករៀបចំគោល-នយោបាយ។ ទីមួយ AFC បានផ្ដោតសំខាន់លើគោលនយោបាយពាក់ព័ន្ធនឹងហានិភ័យ ដែលកើតចេញទីផ្សារហិរញ្ញវត្ថុ និងលំហូរចេញនៃមូលធន។ ទីពីរ AFC បានបង្ហាញឱ្យឃើញពីល្បឿន និងឥទ្ធិពលនៃការ-រាលដាលពីសេដ្ឋកិច្ចមួយទៅសេដ្ឋកិច្ចផ្សេងៗទៀត។ ទី៣ AFC បង្ហាញឱ្យឃើញពីតម្រូវជាចាំបាច់ក្នុងការប្រើប្រាស់ក្របខ័ណ្ឌគោលនយោបាយក្នុងស្រុកប្រកបដោយភាពបត់បែន និងអាចឆ្លើយតបទៅនឹងបញ្ហាកាន់តែឆាប់រហ័សជាងមុន ជាមួយនឹងសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ដែលកាន់តែមានភាពទូលំទូលាយជាងមុន ដើម្បីអាចទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ។
- ភាពមិនប្រាកដប្រជានៃគោលនយោបាយសកលបច្ចុប្បន្ន ដែលរួមមានភាពមិនប្រាកដប្រជាដែលកើតចេញពីបញ្ហាមិនពាក់ព័ន្ធនឹងសេដ្ឋកិច្ច តម្រូវឱ្យអ្នករៀបចំគោលនយោបាយរក្សាឱ្យបាននូវការអនុវត្តគោលនយោបាយស្របតាមគោលការណ៍ច្បាស់លាស់ (Policy Discipline) និងធ្វើការឆ្លើយតបប្រកបដោយភាពបត់បែន ទៅនឹងបម្រែបម្រួលដ៏ឆាប់រហ័សនៃបរិបទសេដ្ឋកិច្ចសកល, សហការជាមួយភ្នាក់ងារគោលនយោបាយរបស់រដ្ឋាភិបាលផ្សេងៗ និងធានាឱ្យបានថា ទីផ្សារយល់ច្បាស់ពីគោលដៅនៃគោលនយោបាយ ដែលបាននិងកំពុងដាក់ចេញ។ ក្រៅពីបញ្ហាប្រឈមរយៈពេលខ្លីទាំងនេះ តំបន់អាស៊ានបូកបី ក៏កំពុងប្រឈមផងដែរនឹងបញ្ហារចនាសម្ព័ន្ធដែលរាំងស្ទះដល់កំណើនសេដ្ឋកិច្ច ដែលរួមមានទាំងបញ្ហាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងធនធានមនុស្ស ដែលលេចចេញកាន់តែច្បាស់ក្នុងបរិបទដែលកំណើនសេដ្ឋកិច្ចកាន់តែថយចុះ។ ដូច្នេះ ការពន្លឿននៃការកែទម្រង់រចនាសម្ព័ន្ធដើម្បីដោះស្រាយដោយផ្ទាល់នូវបញ្ហាអប្រសិទ្ធភាពនានា គឺជាការងារបន្ទាន់ និងចាំបាច់។
- តួនាទីចម្បងរបស់សំណាញ់សុវត្ថិភាពសកល និងតំបន់ (Global and regional financial safety nets) ជាពិសេស CMIM ក្នុងការបង្កើនទ្រនាប់ការពារសេដ្ឋកិច្ច ដើម្បីទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិខាងក្រៅ និងហានិភ័យពីការរាលដាលនៃវិបត្តិនានា កាន់តែមានសារៈសំខាន់នៅក្នុងបរិបទសកលនាពេលបច្ចុប្បន្ននេះ។ ការប្រកាន់ខ្ជាប់នូវការប្ដេជ្ញាចិត្តរបស់អ្នករៀបចំគោលនយោបាយចំពោះកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុតំបន់ នឹងរួមចំណែកទ្រទ្រង់ទំនុកចិត្តទីផ្សារ (Market expectations) និងថែមទាំងផ្ដល់នូវមូលដ្ឋានគោលនយោបាយរឹងមាំ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍក្នុងតំបន់ទាំងមូល។